**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ដីព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ សម្រាប់សម្បទានដីសង្គមកិច្ច ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាស ឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ

www.pheakdeylaw.com

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធី នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**មាត្រា ១.-**

ត្រូវបានផ្ទេរដីព្រៃរេចរិលទំហំ ៤៧៤,៩៤ ហិកតា (បួនរយចិតសិបបួនហិកតា និងកៅសិបបួនអា) ចេញពីដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ស្ថិតនៅក្នុងឃុំត្រស់ និងឃុំគគីរ ស្រុករមាសហែក ខេត្តស្វាយរៀង ដែលកំណត់ដោយបណ្តាចំណុចគោល ដែលមាននិយាមកានៃប្រព័ន្ធកូអ័រដោណេ UTM, Zone 48 N Datum Indian 1960 : ពីចំណុច ១ ដល់ចំណុច ១៧ និងពីចំណុច ១៨ ដល់ចំណុច ២៦ :

១ (៥៩២៩៤៥, ១២៧៤៣៧៤), ២ (៥៩៣១០៦, ១២៧៥៤៥៥), ៣ (៥៩២០៤១, ១២៧៦៤០៣), ៤ (៥៩២៩៣៨, ១២៧៧៨៥២), ៥ (៥៩២៤១៥, ១២៧៧៨៨៤), ៦ (៥៩២៣៨៧, ១២៧៨១៣០), ៧ (៥៩២១៦០, ១២៧៧៩៨៦), ៨ (៥៩១៣៣៤, ១២៧៦៣៧៧), ៩ (៥៩០៨០២, ១២៧៦៣០៤), ១០ (៥៩០២២៤, ១២៧៥៩៦២), ១១ (៥៨៩៦៧៤, ១២៧៥៦២៤), ១២ (៥៨៩៦៧៤, ១២៧៥៣៥៤), ១៣ (៥៩០៧៣០, ១២៧៥៣៥៣), ១៤ (៥៩១០៥០, ១២៧៥៦៨៧), ១៥ (៥៩១១៥៩, ១២៧៥៧១១), ១៦ (៥៩២០៥០, ១២៧៥៣១៦), ១៧ (៥៩២៤៥៥, ១២៧៤៤៥០) ១៨ (៥៩០០៨០, ១២៧២៩៧០), ១៩ (៥៩០០២៩, ១២៧២៦៤១), ២០ (៥៨៩៨០៤, ១២៧១១៨៦), ២១ (៥៨៩៨៣៩, ១២៧១០២៨), ២២ (៥៩០០១៩, ១២៧០៨៩៥), ២៣ (៥៩០៦៥១, ១២៧០៨៤២), ២៤ (៥៩០៤៨២, ១២៧១១៣០), ២៥ (៥៩០១៥០, ១២៧១១៧៦), ២៦ (៥៩០១៤២, ១២៧១៣៧២) ដូចមានផែនទីភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ៤៧៤,៩៤ ហិកតា (បួនរយចិតសិបបួនហិកតា និងកៅសិបបួនអា) ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

www.pheakdeylaw.com

**មាត្រា ៣.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីរដ្ឋ ជូនអាជ្ញាធរកាន់កាប់ដីរដ្ឋ ខេត្តស្វាយរៀង ដើម្បីចុះបញ្ជីជាដីឯកជនរបស់រដ្ឋទំហំ ៤៧៤.៩៤ ហិកតា (បួនរយចិតសិបបួនហិកតា និងកៅសិបបួនអា) ដូចមានចែងក្នុងមាត្រា ២ នៃអនុក្រឹត្យនេះ សម្រាប់គោលដៅសម្បទានដីសង្គមកិច្ច តាមនីតិវិធីច្បាប់ជាធរមាន។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៩

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

www.pheakdeylaw.com




តារាងនិយាមការ

Projection Indian 1960 UTM zone 48N

| Points_ID | Easting (m) | Northing (m) |
|---|---|---|
| 1 | 592945 | 1274374 |
| 2 | 593106 | 1275455 |
| 3 | 592041 | 1276403 |
| 4 | 592938 | 1277852 |
| 5 | 592415 | 1277884 |
| 6 | 592387 | 1278130 |
| 7 | 592160 | 1277986 |
| 8 | 591334 | 1276377 |
| 9 | 590802 | 1276304 |
| 10 | 590224 | 1275962 |
| 11 | 589674 | 1275624 |
| 12 | 589674 | 1275354 |
| 13 | 590730 | 1275353 |
| 14 | 591050 | 1275687 |
| 15 | 591159 | 1275711 |
| 16 | 592050 | 1275316 |
| 17 | 592455 | 1274450 |
| 18 | 590080 | 1272970 |
| 19 | 590029 | 1272641 |
| 20 | 589804 | 1271186 |
| 21 | 589839 | 1271028 |
| 22 | 590019 | 1270895 |
| 23 | 590651 | 1270842 |
| 24 | 590482 | 1271130 |
| 25 | 590150 | 1271176 |
| 26 | 590142 | 1271372 |

www.pheakdeylaw.com